# ធម្មទេសនារបស់លោកអភិបាលអូលីវីយេ
# អភិបូជាទិវានៃការត្រាស់ហៅនៅភ្នំពេញថ្មី
# ថ្ងៃទី១២ ខែឧសភា ឆ្នាំ២០១៩
# **កូនអើយ! សូមអញ្ជើញមកតាមខ្ញុំ**

**អត្ថបទទី១៖ កិច្ចការ ១៣,១៤.៤៣-៥២**

ព្រះអម្ចាស់បានបង្គាប់មកយើងខ្ញុំថា៖ "យើងបានតែងតាំងអ្នកឲ្យធ្វើជាពន្លឺ បំភ្លឺជាតិសាសន៍នានា និងឲ្យនាំការសង្គ្រោះរហូតទៅដល់ ស្រុកដាច់ស្រយាលនៃផែនដី"។ កក ១៣,៤៧

**អត្ថបទទី២៖ វិវរណៈ ៧,៩.១៤ខ-១៧**

ដ្បិតកូនចៀមដែលគង់នៅកណ្ដាលបល្ល័ង្ក ទ្រង់នឹងឃ្វាលពួកគេ ព្រះអង្គនឹងនាំគេទៅរកប្រភពទឹកដែលផ្ដល់ជីវិត ហើយព្រះជាម្ចាស់នឹងជូតទឹកភ្នែកចេញអស់ពីភ្នែករបស់គេ។ វវ ៧,១៧

**ដំណឹងល្អ៖ យ៉ូហាន ១០,២៧-៣០**

ចៀមរបស់ខ្ញុំតែងស្ដាប់សំឡេងខ្ញុំ ខ្ញុំស្គាល់ចៀមទាំងនោះ ហើយចៀមទាំងនោះមកតាមខ្ញុំ។ យហ ១០,២៧

បងប្អូនជាទីស្រឡាញ់!

ថ្ងៃនេះ យើងពោរពេញដោយអំណរសប្បាយដោយនឹករលឹកដល់ព្រះយេស៊ូដែលជាគ្រូគង្វាលដ៏សប្បុរស។ ថ្ងៃនេះយើងជួបជុំគ្នានៅទីនេះ ដោយសារយើងបានស្ដាប់ព្រះបន្ទូលរបស់ព្រះយេស៊ូពីម្សិលមិញ "**សូមអញ្ជើញមកអ្នកនឹងឃើញ**" ព្រះយេស៊ូមានព្រះបន្ទូលនេះសម្រាប់យើងទាំងអស់ សូមអញ្ជើញមកអ្នកនឹងឃើញ អ្នកនឹងស្ដាប់ឮ និងយល់យ៉ាងច្បាស់ថា **តើខ្ញុំជានរណា?** យើងបានធ្វើដំណើរពីគ្រប់ទីកន្លែងក្នុងប្រទេសកម្ពុជា ដោយសារមានលោកបូជាចារ្យ មានបងប្រុសបងស្រី ដែលបានអញ្ជើញយើងឲ្យមកដោយនាមព្រះយេស៊ូ។

អាទិភាពរបស់យើង គឺឲ្យយើងអធិដ្ឋាន មានសកម្មភាពសម្រាប់ការត្រាស់ហៅ នៅសម័យខ្ញុំពេលលោកបូជាចារ្យទេសនាអំពីការត្រាស់ហៅ គាត់និយាយទូទៅមែនទែនគាត់ភ័យខ្លាចនិយាយអំពីជីវិតជាបូជាចារ្យ ជីវិតជាបងប្រុសបងស្រី យើងខ្លាចយុវជនគិតថាយើងចង់ចាប់គេឲ្យគេធ្វើជាបូជាចារ្យឬបងប្រុសបងស្រី។ ប៉ុន្តែ ខ្ញុំគិតថាយើងគិតខុសយើងបានឃើញលទ្ធផលនៅប្រទេសបារាំងអ្នកដែលចូលទេវវិទ្យាល័យតិចទៅៗ។ ដូច្នេះថ្ងៃនេះ ជាអាទិត្យទី៤នៃរដូវបុណ្យចម្លងជាពេលវេលាដើម្បីអធិដ្ឋាន ដើម្បីនិយាយយ៉ាងច្បាស់លាស់អំពីជីវិតជាបូជាចារ្យ

ជីវិតជាបងប្រុសបងស្រី។ នេះជាតួនាទីយើងជាបូជាចារ្យ ជាបងប្រុសបងស្រី ដើម្បីត្រាស់ហៅយុវជនយុវនារីឲ្យភ្ញាក់ស្មារតី ឲ្យយើងសាបព្រោះយ៉ាងទូលំទូលាយដូចព្រះយេស៊ូពីដើម។

ថ្ងៃនេះ ជាអាទិត្យទី៤នៃរដូវបុណ្យចម្លង នៅក្នុងពិភពលោកទាំងមូលយើងអធិដ្ឋានសម្រាប់ការត្រាស់ហៅ។ ថ្ងៃនេះ ជាលើកទី១០ដែលយើងបានធ្វើទិវានៃការត្រាស់ហៅសម្រាប់ភូមិភាគទាំង៣ វាជាពេលវេលាសម្រាប់យើងដែលជាបងប្រុសបងស្រី លោកបូជាចារ្យ លោកអភិបាល យកចិត្តទុកដាក់មកទីនេះដើម្បីអធិដ្ឋានជាមួយយុវជនយើង ដើម្បីជួយកសាងព្រះសហគមន៍នៅក្នុងប្រទេសកម្ពុជា។ យើងត្រូវការគិតពិចារណា អាទិភាពរបស់យើងដល់ណាព្រះយេស៊ូបាននិយាយច្បាស់ណាស់ យើងត្រូវការលះបង់ចោល។ ពេលយុវជនជាអ្នកមានចង់ដើរតាមព្រះជាម្ចាស់ គាត់បានធ្វើយ៉ាងច្រើនដែលល្អ ប៉ុន្តែគាត់ខ្វះតែមួយគឺគាត់មិនហ៊ានលក់ទ្រព្យសម្បត្តិរបស់គាត់នឹងចែកជាមួយអ្នកក្រីក្រ។ ដូច្នេះ យើងត្រូវការគិតអំពីអត្ថបទគម្ពីរនេះដែរសម្រាប់យើងជាអ្នកបួស ប្រសិនបើយើងរៀបចំប្រជុំនៅថ្ងៃនេះ យើងលះបង់ចោលអ្វីខ្លះ? អាទិភាពរបស់យើងនៅឯណា?

បងប្អូនជាទីស្រឡាញ់!

ថ្ងៃនេះយើងពោរពេញដោយអំណរសប្បាយ ដោយដឹងថាព្រះយេស៊ូអញ្ជើញយើងផ្ទាល់ខ្លួនឲ្យមកនៅទីនេះដើម្បីមើល ដើម្បីស្តាប់ ដើម្បីឃើញព្រះយេស៊ូផ្ទាល់។ ប៉ុន្តែ ដើម្បីមើល ដើម្បីឃើញ ដើម្បីស្តាប់ព្រះសហគមន៍ ដោយសារព្រះយេស៊ូយើងមើលឃើញនៅក្នុងគម្ពីរ នៅក្នុងព្រះកាយដែលយើងទទួល ប៉ុន្តែយើងឃើញព្រះយេស៊ូនៅក្នុងវត្តមានព្រះសហគមន៍។ នៅពេលយើងឃើញ ព្រះសហគមន៍របស់យើងដែលជាមហាគ្រួសារ យើងឃើញវត្តមានរបស់ព្រះយេស៊ូយ៉ាងពិតប្រាកដ យើងឃើញព្រះយេស៊ូដែលស្រឡាញ់យើងនៅក្នុងមហាគ្រួសារនេះ។ ដូច្នេះ សូមឪពុកម្តាយជួយអធិដ្ឋានសម្រាប់កូនៗ ឲ្យគេចាប់ផ្តើមភ្ជាប់ជាមួយព្រះយេស៊ូ ប្រសិនបើមានកូនណាម្នាក់ដែលចង់បម្រើព្រះសហគមន៍អស់មួយជីវិត សូមឯកភាព និងជម្រុញគាត់ទៅដោយសារយើងដឹងថា ជីវិតដែលយើងទទួលជាជីវិតអស់កល្បជានិច្ច។

ថ្ងៃនេះ ព្រះយេស៊ូមានសំណួរមួយយ៉ាងពិសេសសម្រាប់យើង ព្រះអង្គសួរដល់យើងម្នាក់ៗថា "**កូនអើយ! តើអ្នកស្រឡាញ់ខ្ញុំឬទេ?**" ដូចព្រះយេស៊ូធ្លាប់សួរដល់លោកសិលាដែរ។ យើងឃើញក្រុមគ្រីស្តទូតខិតខំប្រកាសដំណឹងល្អអស់ពីសមត្ថភាព ប៉ុន្តែក្រុមគ្រីស្តទូតនៅពេលជួបជាមួយជនជាតិយូដា គេចាប់ផ្តើមរអ៊ូរទាំជាពិសេសបូជាចារ្យដោយសារគេមិនចង់ទទួលស្គាល់របៀបដែលព្រះយេស៊ូមានជីវិតរស់ឡើងវិញ។ ដូច្នេះ ក្រុមគ្រីស្តទូតគេបាននិយាយថា "**ដោយ**

**បងប្អូនបដិសេធមិនព្រមទទួលព្រះបន្ទូលនេះ ហើយដោយសារបងប្អូនយល់ឃើញថាខ្លួនឯងមិនសមទទួលជីវិតអស់កល្បជានិច្ចទេ យើងបានប្រកាសដល់សាសន៍ដទៃវិញ**”។ ថ្ងៃនេះ យើងមានសេចក្តីសុខ យើងមានអំណរសប្បាយ ដោយសារយើងបានឆ្លើយតបទៅព្រះយេស៊ូ ដើម្បីទទួលពិធីជ្រមុជទឹក ដើម្បីទទួលជីវិតនៅលើផែនដីនេះ ប៉ុន្តែលើសពីនេះទៀតយើងយល់ថាយើងសុំទទួលជីវិតអស់កល្បជានិច្ចរួមជាមួយព្រះយេស៊ូ។ រួមជាមួយព្រះយេស៊ូដែលស្រឡាញ់យើង រួមជាមួយព្រះយេស៊ូដែលធ្វើដំណើរជាមួយយើង រួមជាមួយព្រះយេស៊ូដែលជាគ្រូគង្វាលដ៏សប្បុរសដែលមានសម្លេងមួយយ៉ាងពិសេស ណែនាំឲ្យយើងរៀងៗខ្លួនពេលយើងស្តាប់ឮសម្លេងហ្នឹងយើងដឹងភ្លាមនេះជាព្រះយេស៊ូ ដែលកំពុងគោះទ្វារនៃដួងចិត្តរបស់យើង ជាព្រះយេស៊ូដែលកំពុងមានព្រះសូរសៀងសម្រាប់ជីវិតរបស់ខ្ញុំ។ ព្រឹកឡើង នៅពេលស្រ្តីៗមកដល់គេមើលមិនស្គាល់ព្រះយេស៊ូទេ ប៉ុន្តែពេលព្រះយេស៊ូមានព្រះបន្ទូលតែមួយម៉ាត់ថា “**ម៉ារី**” គាត់ភ្ញាក់ទោះបីគាត់មើលមិនស្គាល់ជាព្រះយេស៊ូ តែរបៀបដែលព្រះយេស៊ូហៅគាត់ ណែនាំឲ្យគាត់ដឹងភ្លាមថានេះជាព្រះអម្ចាស់ដែលបានហៅគាត់។

ព្រះយេស៊ូ ជាគ្រូគង្វាលដ៏សប្បុរសដែលត្រាស់ហៅយើង ដែលស្គាល់យើង ជាពិសេសដែលណែនាំយើងឲ្យយើងមានជីវិតអស់កល្បជានិច្ច។ យើងបានគិតអំពីសុបិន អំពីទស្សនៈវិស័យសម្រាប់អនាគតលើផែនដីនេះ យើងក៏អាចគិតអំពីសុបិនរបស់យើងដ៏អស្ចារ្យ អំពីអនាគតអស់កល្បជានិច្ចរបស់យើង។ ពេលយើងស្លាប់ហើយ យើងមិនមែនទៅជាធូលីគឺយើងចូលនៅក្នុងជីវិតអស់កល្បជានិច្ច។ ដូច្នេះគម្រោងការរបស់ព្រះជាម្ចាស់ មិនមែនជាគម្រោងការតូចដែលមានព្រំដែនលើផែនដីនេះ តែជាគម្រោងការដ៏ធំធេងដែលគ្មានព្រំដែន ដើម្បីឆ្លងសេចក្តីស្លាប់ទៅដល់ជីវិតអស់កល្បជានិច្ច។ គម្រោងការរបស់ព្រះជាម្ចាស់ មិនមែន១៥០ឆ្នាំលើផែនដីនេះគឺអស់កល្បជានិច្ចសម្រាប់យើងនៅថ្ងៃអនាគត។ យើងពោរពេញដោយអំណោយទានរបស់ព្រះអង្គ និងជាពិសេសតម្លៃថ្លៃថ្នូរដោយដឹងថា ជីវិតរបស់យើងអាចនៅស្ថិតស្ថេររួមជាមួយព្រះជាម្ចាស់ និងណែនាំឲ្យយើងដូចនៅក្នុងអត្ថបទទីពីរ “**ពួកគេនឹងលែងឃ្លាន លែងស្រេកទៀតហើយ ព្រះអាទិត្យ និងកំដៅគ្រប់យ៉ាង ក៏នឹងលែងធ្វើទុក្ខគេទៀតដែរ**” យើងរស់នៅក្នុងសេចក្តីសុខហើយ។ នៅពេលយើងរស់នៅជាមួយព្រះជាម្ចាស់ យើងលែងរវីរវល់នឹងបញ្ហាដើម្បីចិញ្ចឹមជីវិតលើផែនដីទៀតទេ យើងពោរពេញដោយសេចក្តីសុខជាមួយព្រះជាម្ចាស់។

អ្វីដែលលោកប៉ូលបានទទួល “**យើងបានតែងតាំងអ្នកឲ្យធ្វើជាពន្លឺ បំភ្លឺជាតិសាសន៍នានា និងឲ្យនាំការសង្គ្រោះរហូតដល់ស្រុកដាច់ស្រយាលនៃផែនដី**” នេះជាតួនាទីរបស់យើង។ មិនមែនតែលោកប៉ូលមិនមែនតែគ្រីស្តទូត គឺយើងទាំងអស់បានទទួលការតែងតាំងមួយយ៉ាងពិសេស

ដើម្បីធ្វើជាពន្លឺបំភ្លឺជាតិសាសន៍នានា និងនាំការសង្គ្រោះរហូតដល់ស្រុកដាច់ស្រយាលនៃផែនដី។ ពេលយើងស្តាប់នេះ ណែនាំឲ្យយើងពោរពេញដោយសេចក្តីសុខនិងអំណរសប្បាយ។ ក្រុមគ្រីស្តទូតពីដើម គេចេញពីទីក្រុងមួយទៅទីក្រុងមួយ គេមកដល់ទីក្រុងរ៉ូម ក្រោយមកគេមកដល់ប្រទេសជប៉ុន ប្រទេសចិន ប្រទេសកម្ពុជាយើង៤៦៥ឆ្នាំមុនដើម្បីចាប់ផ្តើមប្រកាសដំណឹងល្អ។ ឲ្យយើងគិត **តើនៅទីនេះមានប៉ុន្មាននាក់ដែលសុខចិត្តលះបង់ចោលលើសពីនេះទៅទៀត?** មិនមែនប្រកាសល្មមៗទេ តែដោយដឹងថាខ្ញុំសុខចិត្តដើរតាមព្រះយេស៊ូដោយសារព្រះអង្គកំពុងទតមើលមកខ្ញុំពោរពេញដោយព្រះហឫទ័យស្រឡាញ់។ ព្រះយេស៊ូមានព្រះបន្ទូលមកខ្ញុំថា "**កូនអើយ! សូមអញ្ជើញមកតាមខ្ញុំ**"។ ដូចក្រុមគ្រីស្តពីដើម គេកំពុងនេសាទត្រីពេលព្រះយេស៊ូមានព្រះបន្ទូលដូចនេះគេមិនខ្លាចអ្វីទេ គេបោះចោលអ្វីៗទាំងអស់ហើយដើរតាមព្រះយេស៊ូ។

ជីវិតរបស់យើងសព្វថ្ងៃនៅក្នុងស្ថានភាពហ្នឹង យើងមើលសង្គម យើងមើលលោកីយ៍ យើងមើលព្រះសហគមន៍ យើងមើលស្ថានបរមសុខ ហើយយើងគិត **តើសុភមង្គលយ៉ាងពិតប្រាកដខ្ញុំរកឃើញនៅកន្លែងណា?** ថ្ងៃនេះនៅក្នុងអត្ថបទទីមួយ យើងឃើញផ្លែមួយយ៉ាងពិសេសគឺអំណរសប្បាយ "**សាសន៍ដទៃដែលបានទទួលពិធីជ្រមុជទឹក ពោរពេញដោយអំណរសប្បាយ និងសាវ័កទោះបីបានទទួលការបៀតបៀនក៏ទទួលបានអំណរសប្បាយដែរ**" សាវ័កដែលប្រកាសដំណឹងល្អ និងសាសន៍ដទៃដែលបានទទួលជីវិតថ្មីតាមរយៈពិធីជ្រមុជទឹក ពោរពេញដោយអំណរសប្បាយ នេះជាផ្លែ។ យើងមកពីព្រះជាម្ចាស់ រស់នៅក្នុងលោកីយ៍ដើម្បីបម្រើលោកីយ៍ ណែនាំឲ្យលោកីយ៍ទទួលសេចក្តីសុខ។ ព្រះរាជ្យរបស់ព្រះជាម្ចាស់ គឺណែនាំឲ្យមនុស្សយើងពោរពេញដោយសុភមង្គលយ៉ាងពិតប្រាកដ ព្រះយេស៊ូមានព្រះជន្មគង់នៅជាមួយយើងថ្ងៃនេះ។ សុភមង្គលយ៉ាងពិតប្រាកដ គឺព្រះយេស៊ូដែលចាប់ដៃខ្ញុំ ហើយមានព្រះបន្ទូលបំភ្លឺមកខ្ញុំ ដើម្បីណែនាំឲ្យមនុស្សលោកមានជីវិតថ្មីរស់នៅក្នុងសង្គមបច្ចុប្បន្ននេះ។ ដូច្នេះ យើងត្រូវការមានលោកបូជាចារ្យ មានបងប្រុសបងស្រី ច្រើនដើម្បីធ្វើដំណើរជាមួយព្រះយេស៊ូតទៅទៀត ដើម្បីណែនាំមនុស្សយ៉ាងច្រើនចូលនៅក្នុងមិត្តភាពជាមួយព្រះយេស៊ូ។

យើងពោរពេញដោយសេចក្តីសង្ឃឹម យើងពោរពេញដោយអំណរសប្បាយ ហើយយើងស្តាប់និងស្តាប់ម្តងទៀតថា "**សូមអញ្ជើញមកតាមខ្ញុំ ខ្ញុំណែនាំឲ្យមានជីវិតអស់កល្បជានិច្ច និងមានសុភមង្គលដ៏ពិតប្រាកដ**"។ អាម៉ែន៕